00933662

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (២៥)

ឯកសារលេខ E264/1/2/2

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jun-2013, 14:39
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (២៥)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (25)

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រម Agniezska KLONOWIECKAMILART**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម Judge Florence Ndepele Mwachande MUMBA**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣**

**ភាសាដើម៖** **ខ្មែរ/អង់គ្លេស/បារាំង**

**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចស្តាប់សក្ខីកម្មសាក្សីជំនាញ មុនពេលចេញសេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី

---

**សហព្រះរាជអាជ្ញា**

ជា លាង

**ជនជាប់ចោទ**

ខៀវ សំផន

00933663



Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

Jacques VERGÈS

1. **អង្គជំនុំជម្រះតុលាការកំពូល** ("អ.ជ.ត.ក") នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ បានទទួលបណ្តឹងសាទុក្ខដែលបានដាក់កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ដោយមេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី") ប្រឆាំងនឹងសេចក្តីសម្រេចស្តាប់សក្ខីកម្មសាក្សីជំនាញ Phillip SHORT និង Elizabeth BECKER ("បណ្តឹងសាទុក្ខ") មុនពេលចេញសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ("សេចក្តីសម្រេចដែលរងការជំទាស់")[1]។ មិនមានការដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខនេះទេ។

2. កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានចេញ "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១"[2] ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក") ដោយអង្គជំនុំជម្រះបានប្រកាសថា អានុភាពនៃកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវគ្នាទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ បណ្តាលឱ្យដីកាបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២នេះ មោឃភាព[3]។ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ច្បាស់ថា សេចក្តីសម្រេចរបស់ អ.ជ.ត.ក គឺមិនបានធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២នោះទេ ប៉ុន្តែ "អង្គជំនុំជម្រះត្រូវអញ្ជើញភាគីនានាដាក់សារណារបស់ខ្លួនលើលក្ខខណ្ឌនៃដីកានេះ ហើយនៅពេលដែលអត្ថប្រយោជន៍របស់ភាគី *ទាំងអស់* ត្រូវបានធ្វើឱ្យមានតុល្យភាពចំពោះកត្តាពាក់ព័ន្ធផ្សេងៗហើយនោះ ការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ អាចធ្វើទៅបានប្រកបដោយភាពសមស្រប"[4]។

---

[1] *បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចចេញតាមរយៈអ៊ីមែលរបស់លោកស្រី Susan LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣* ឯកសារE264/1/2/1 ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ *សំដៅទៅលើ* អ៊ីមែលអេឡិចត្រូនិករបស់លោកស្រី Susan LAMB មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ "គោលការណ៍ណែនាំដល់ភាគីនានាបន្ទាប់ពីមានសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី" ផ្ញើកាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ៣:១៤នាទីរសៀល។ *សូមមើល* បណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ ២៖ អ៊ីមែលរបស់Susan LAMB ឯកសារ E264/1/2/1.3 ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ("ឧបសម្ព័ន្ធ ២")។

[2] ឯកសារ E163/5/1/13

[3] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៤៩។

[4] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០ (គូសបញ្ជាក់បន្ថែមនៅក្នុងសំណៅដើម)។

បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូង បានចេញភ្លាមៗនូវអនុស្សរណៈក្នុងការកំណត់កាលបរិច្ឆេទសវនាការដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៤ និងទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងបានបញ្ចូលនូវបញ្ហាលំអិតជាក់លាក់ចំនួនប្រាំបួន ដែលទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ សម្រាប់ឲ្យភាគីលើកឡើង[5]។ ក្រោយមក សវនាការ ត្រូវបានលើកកាលបរិច្ឆេទទៅថ្ងៃទី ១៨ និង ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣[6]។

3. ក្រោយពីការលើកសេចក្តីសន្និដ្ឋានដែលត្រូវបានស្តាប់កាលពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈផ្សេងមួយទៀតកាលពីថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស្នើសុំព័ត៌មានបន្ថែម[7] ដែលភាគីបានផ្តល់នូវព័ត៌មានបន្ថែមនេះក្នុងអំឡុងសវនាការកាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣[8]។ អង្គជំនុំជម្រះសាលាដំបូង បានអញ្ជើញឲ្យភាគីនានាផ្តល់នូវមតិយោបល់ទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះ ក្នុងចំណោមបញ្ហាផ្សេងទៀត ដែលបានលើកឡើងថា ប្រសិនបើសក្ខីកម្មរបស់សាក្សីជំនាញ Philip SHORT និង Elizabeth BECKER មិនអាចស្តាប់សក្ខីកម្មមុនពេលការចេញសេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ បានទេ "ប្រហែលជាអង្គជំនុំជម្រះនឹងបាត់បង់នូវឱកាសក្នុងការស្តាប់សក្ខីកម្មរបស់ពួកគាត់ទាំងស្រុងតែម្តង"[9]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង ស្នើសុំទស្សនៈរបស់ភាគីថាតើសក្ខីកម្មរបស់ Philip SHORT និង Elizabeth BECKER ព្រមទាំងសាក្សីផ្សេងៗចំនួនបួនរូបទៀត ដែលបានគ្រោងឲ្យមកផ្តល់សក្ខីកម្ម "ឆាប់ៗ" គួរតែពន្យារពេលស្តាប់សក្ខីកម្មរហូតដល់ក្រោយពីការចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើការបំបែកកិច្ចដំណើរការនីតិវិធី ដែរ

---

[5] អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ "ការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13)" ឯកសារ E163/5/1/13/1 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងបានដាក់កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[6] ប្រតិចារឹកចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារE1/171.1 ទំព័រ ៦, ៨៥។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/172.1។

[7] អនុស្សរណៈរបស់លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ៖ "សំណួរបន្ថែមទៅភាគីក្រោយសវនាការថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បន្ទាប់ពីមានសេចក៏តសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13)" ឯកសារ E264 ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("អនុស្សរណៈបន្ថែម")។

[8] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារE1/173.1។

[9] អនុស្សរណៈបន្ថែម កថាខណ្ឌ ៣ (iii)។

ឬទេ ឬ“ថាតើសាក្សីអាចផ្តល់សក្ខីកម្មយ៉ាងហោចណាស់ទៅលើវិសាលភាពនៃអង្គហេតុដែលបានកំណត់រួចហើយដោយភាគីទាំងអស់មុនពេលមានមោឃភាពដីកាបំបែកកិច្ចដំណើរការនីតិវិធី ព្រមទាំងសេចក្តីសម្រេចដែលពាក់ព័ន្ធនានាដែរឬទេ?”[10]។

4. កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកទឡ្ហីករណ៍ថា វាមិនមានមូលហេតុត្រឹមត្រូវតាមច្បាប់ ដែលមិនអាចស្តាប់សក្ខីកម្មរបស់ Philip SHORT និង Elizabeth BECKER ដូចដែលបានគ្រោងទុកនោះទេ[11]។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តីទាំងអស់ប្រកាន់នូវជំហរថា មិនមានសាក្សីណា គួរតែត្រូវបានស្តាប់សក្ខីកម្ម រហូតដល់ក្រោយពេលការចេញសេចក្តីសម្រេចថ្មីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២នោះទេ[12]។ បីម៉ោងក្រោយពីការបញ្ចប់សវនាការមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគីតាមរយៈការផ្ញើសារអេឡិចត្រូនិក ដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

> អង្គជំនុំជម្រះនឹងដំណើរការស្តាប់អ្នកជំនាញ Philip SHORT នៅសប្តាហ៍ដែលចាប់ផ្តើមនៅថ្ងៃ ចន្ទ ទី ៤ ខែ មីនា ឆ្នាំ ២០១៣ និងអ្នកជំនាញ Elisabeth BECKER នៅក្នុងអំឡុងសប្តាហ៍ដែលចាប់ផ្តើមនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ ដូចដែលបានកំណត់ពេលវេលាកាលពីមុន។ ស្របតាមការណែនាំកាលពីមុនរបស់អង្គជំនុំជម្រះ អ្នកជំនាញទាំងពីររូបអាចនឹងត្រូវបានចោទសួរអំពីសំណុំរឿង ០០២ ទាំងមូល នៅត្រង់ចំណុចទាំងឡាយណាដែលអ្នកជំនាញទាំងពីររូបបានដឹង រីឯភាគីនានាត្រូវបានលើកទឹកចិត្តឱ្យផ្តោតការចោទសួរទៅលើចំណុចទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងអង្គហេតុនានា ដែលជាបញ្ហាចោទនៅក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងនឹងមិនស្តាប់សក្ខីកម្មរបស់បុគ្គលផ្សេងទៀតដែល

[10] អនុស្សរណៈបន្ថែម កថាខណ្ឌ ៣ (iv)។

[11] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/173.1 ទំព័រ ១៥-១៦ (សហព្រះរាជអាជ្ញា), ទំព័រ ៣៩ (សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី)។

[12] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/173.1 ទំព័រ ២៦-២៧ (នួន ជា), ៣០-៣២ (អៀង សារី), ៣៦-៣៧ (ខៀវ សំផន)។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/172.1 ទំព័រ១៤-១៥ (នួន ជា), ទំព័រ៤៨ (អៀង សារី)។

រៀបនឹងកើតមានឡើង មុនពេលអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចរបស់ខ្លួននោះទេ[13]។

5. កាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ មេធាវីការពារក្តី បានបញ្ជាក់អំពីចេតនារបស់ខ្លួនក្នុងការប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចដែលរងការជំទាស់ ដោយបានផ្ញើជូននូវសំណៅថតចម្លងបណ្តឹងសាទុក្ខមួយច្បាប់ តាមរយៈការផ្ញើសារអេឡិចត្រូនិក មុនពេលដាក់ឯកសារ[14]។ ប៉ុន្មានម៉ោងក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយលើកឡើងសាជាថ្មីថា សក្ខីកម្មរបស់ Philip SHORT និង Elizabeth BECKER នឹងត្រូវស្តាប់សក្ខីកម្ម "ដូចដែលបានគ្រោងទុកកាលពីពេលមុន" និងបានបញ្ជាក់ច្បាស់ថា ដោយសារតែអ្នកជំនាញទាំងពីររូប នឹងត្រូវបានសួរសំណួរទាក់ទិននឹងប្រធានបទទាំងអស់ដែលមាននៅក្នុងសំណុំរឿង០០២ ការស្តាប់សក្ខីកម្មរបស់សាក្សីទាំងនេះ មុនពេលមានការចេញសេចក្តីសម្រេចថ្មីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ ពុំមានប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីឡើយ[15]។

6. កាលពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ មេធាវីការពារក្តីបានស្នើសុំការអនុញ្ញាតអនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[16] ដើម្បីដាក់បណ្តឹងសាទុក្ខជាភាសាបារាំងជាបឋមសិន ដោយឯកសារបកប្រែជាភាសាខ្មែរនៃបណ្តឹងសាទុក្ខនេះ នឹងដាក់ឲ្យបានឆាប់

[13] តុលាការផ្អាកនៅម៉ោង ១២:០៤ ថ្ងៃត្រង់។ *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/173.1 ទំព័រ ៦៨។ អ៊ីមែល ត្រូវបានបញ្ជូននៅម៉ោង ៣:១៤នាទីរសៀល។ *សូមមើល* បណ្តឹងសាទុក្ខ ឧបសម្ព័ន្ធ២។

[14] អ៊ីមែលអេឡិចត្រូនិករបស់ Marie CAPOTORTO អ្នកពិគ្រោះយោបល់ផ្នែកច្បាប់របស់មេធាវីការពារក្តី ដែលមានកម្មវត្ថុ "សេចក្តីណែនាំជូនដាក់ភាគី ក្រោយពីសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី" ដែលផ្ញើការពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ នៅម៉ោង ១០ ព្រឹក។ *សូមមើល បណ្តឹងសាទុក្ខជាបន្ទាន់របស់លោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចតាមរយៈអ៊ីមែលរបស់អ្នកស្រី LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣-សារណាបន្ថែម* ឯកសារ E264/1/2/1/1 ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ("សារណាបន្ថែម") ឧបសម្ព័ន្ធ ៣៖ អ៊ីមែលរបស់ Marie CAPOTORTO ផ្ញើជូន Sheila PAYLAN និង Matteo CRIPPA ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E264/1/2/1/1.4 ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ("ឧបសម្ព័ន្ធបន្ថែម ៣")។

[15] អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ "ការកំណត់កាលបរិច្ឆេទរបស់អ្នកជំនាញ Philip Short និង Elizabeth Becker និងការពន្យារពេលស្តាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹងអង្គហេតុ រហូតដល់មានសេចក្តីសម្រេចថ្មីអំពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ" ឯកសារE264/1 ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("អនុស្សរណៈស្តីពីការកំណត់កាលបរិច្ឆេទ") កថាខណ្ឌ២។

[16] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក វិសោធនកម្មលើកទី៨ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

របស់បំផុត ដោយផ្អែកលើមូលដ្ឋានថា អង្គភាពបកប្រែភាសា (“ITU”) របស់ អ.វ.ត.ក បាន បញ្ជាក់ថា ការបកប្រែឯកសារនេះជាភាសាខ្មែរ មិនអាចបកប្រែចប់នៅមុនថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ នោះទេ ហើយនៅក្នុងបណ្ដឹងសាទុក្ខ មេធាវីការពារក្ដីនឹងស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចរបស់ខ្លួនឱ្យបានមុនថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣[17]។ នៅថ្ងៃជាមួយគ្នានោះ ការស្នើសុំការអនុញ្ញាតឱ្យដាក់បណ្ដឹងសាទុក្ខតែភាសាបារាំង ត្រូវបានបដិសេធចោលដោយផ្អែកលើមូលដ្ឋានថា ករណីពិសេសដែលតម្រូវនៅក្នុងមាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ មិនត្រូវបានបង្ហាញនោះទេ ពីព្រោះតែមានពេលវេលានៅសល់គ្រប់គ្រាន់ ដើម្បីដាក់បណ្ដឹងសាទុក្ខជាភាសាបារាំង និងភាសាខ្មែរ[18] ហើយដោយសារតែកាលៈទេសៈមិនអនុញ្ញាត ឬតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្ដីសម្រេចរបស់ខ្លួនមុនថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣[19]។ អាស្រ័យហេតុនេះ មេធាវីការពារក្ដី ត្រូវបានណែនាំឱ្យដាក់បណ្ដឹងសាទុក្ខរបស់ខ្លួនតាមពេលវេលាកំណត់ និងលក្ខខណ្ឌតម្រូវខាងភាសា ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសេចក្ដីណែនាំអនុវត្ត និងបានធានាអះអាងថា លទ្ធភាពនៃផលប៉ះពាល់ណាមួយដែលកើតចេញមកពីកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែលអាចប្ដឹងឧទ្ធរណ៍បាន នឹងត្រូវដោះស្រាយ*តាមពេលក្រោយ*[20]។

7. កាលពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងមិនអាចដំណើរការសួរដេញដោល Philip SHORT ដោយមូលហេតុការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យសាជាថ្មីរបស់លោក អៀង សារី និងភាពអសមត្ថភាពនៅពេលនោះដែលមិនអាចបោះបង់សិទ្ធិរបស់ខ្លួនដើម្បីចូលរួម

---

[17] សារអេឡិចត្រូនិករបស់ Marie CAPOTORTO អ្នកពិគ្រោះយោបល់ផ្នែកច្បាប់របស់មេធាវីការពារក្ដី ដែលមានកម្មវត្ថុ“*ការស្នើសុំការអនុញ្ញាតឱ្យដាក់ឯកសារជាភាសាបារាំងជាបឋមសិន*” ផ្ញើកាលពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ នៅវេលាម៉ោង ៦:១៣ ព្រឹក។ *សូមមើល* សារណាបន្ថែម ឧបសម្ព័ន្ធ ២ ៖ អ៊ីមែលរបស់ Sheila PAYLAN ផ្ញើជូន Marie CAPOTORTO ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E264/1/2/1/1.3 ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ (“ឧបសម្ព័ន្ធបន្ថែម ២”)។

[18] វិធាន១០៧(១) នៃវិធានផ្ទៃក្នុង អនុញ្ញាតរយៈពេល៣០ថ្ងៃសម្រាប់ការដាក់បណ្ដឹងសាទុក្ខភ្លាមៗ ចាប់ពីថ្ងៃប្រកាសសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

[19] *សូមមើល* ឧបសម្ព័ន្ធបន្ថែម ២។

[20] *សូមមើល* ឧបសម្ព័ន្ធបន្ថែម ២។

សវនាការ ព្រមទាំងអង្គហេតុដែលថា បុគ្គលិកជាតិនៅអង្គភាពបកប្រែភាសា បានធ្វើពហិការ[21]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានពន្យារពេលស្តាប់សក្ខីកម្មរបស់ Philip SHORT និង Elizabeth BECKER ដោយ "ព័ត៌មានទាក់ទងនឹងការកំណត់កាលបរិច្ឆេទជាថ្មី [...] នឹងផ្តល់ជូនក្នុងពេលសមស្រប"[22]។ សាក្សីទាំងនេះ នៅតែមិនទាន់បានស្តាប់សក្ខីកម្មនៅឡើយ នៅពេលដាក់បណ្តឹងសាទុក្ខនេះ កាលពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ។

8. មេធាវីការពារក្តី បានលើកឡើងថា អ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ គឺជាសេចក្តីសម្រេចមួយ[23] ហើយបណ្តឹងសាទុក្ខនេះ អាចទទួលយកបានផ្អែកតាមវិធាន ២១ និងវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង[24]។ មេធាវីការពារក្តី លើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង បានភ័ន្តច្រឡំអង្គច្បាប់ និងមានកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដែលនាំឲ្យមានការខូចខាត ដោយសារតែបានបដិសេធមិនព្រមពន្យារសវនាការលើអង្គសេចក្តីទាំងអស់ រហូតដល់ការចេញសេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី[25]។ ជាពិសេស មេធាវីការពារក្តី តវ៉ាថា ខ្លួនមិនអាចរៀបចំការការពារខ្លួន ឬរបៀបនៃការសួរសំណួរ ឬណែនាំខៀវ សំផន អំពីយុត្តិសាស្ត្ររឿងក្តី នៅពេលដែលមិនមានភាពច្បាស់លាស់ទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ថ្មី និងលក្ខខណ្ឌនានានៃការបំបែកកិច្ចដំណើរការនីតិវិធីថ្មីនោះ[26]។

9. បន្ថែមពីលើនេះ មេធាវីការពារក្តីតវ៉ាថា អង្គហេតុដែលពាក់ព័ន្ធនឹងការពន្យារកិច្ចដំណើរការនីតិវិធី ដែលកើតឡើងដោយសារតែ Philip SHORT និង Elizabeth BECKER មិនទាន់ត្រូវបានស្តាប់សក្ខីកម្មនៅពេលដែលដាក់បណ្តឹងសាទុក្ខ មិនអាចចាត់ទុកថាបណ្តឹងសាទុក្ខនេះ ជាអសារបង់ឡើយ ពីព្រោះដរាបណានៅតែមានលទ្ធភាពនៃការស្តាប់សក្ខីកម្មសាក្សីទាំងនេះមុនពេលការចេញសេចក្តីសម្រេចថ្មីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ផលប៉ះពាល់ដែលទទួលរងនៅតែមានពិតប្រាកដ ហើយទស្សនៈវិស័យនៃការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ត្រូវបានទទួលរងការប៉ះពាល់

---

[21] ប្រតិចារឹកចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E1/174.1 ទំព័រ ៤-៥។ អនុស្សរណៈរបស់ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ "ការពន្យារពេលស្តាប់សក្ខីកម្មអ្នកជំនាញ" ឯកសារ E264/3 ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ ("អនុស្សរណៈស្តីពីការពន្យារពេល") កថាខណ្ឌ១។

[22] អនុស្សរណៈស្តីពីការពន្យារពេល កថាខណ្ឌ១។

[23] បណ្តឹងសាទុក្ខ កថាខណ្ឌ៥-៨។

[24] បណ្តឹងសាទុក្ខ កថាខណ្ឌ៩-២៦។

[25] បណ្តឹងសាទុក្ខ កថាខណ្ឌ២៧-៥៣។

[26] បណ្តឹងសាទុក្ខ កថាខណ្ឌ៣២, ៣៦-៥២។

យ៉ាងធ្ងន់ធ្ងរ[27]។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តា "ចាត់ការជាបន្ទាន់ ឬបង្គាប់ឱ្យផ្អាកកិច្ចដំណើរការនីតិវិធីលើអង្គសេចក្ដី រហូតដល់ពេលចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខនេះ" ប្រកាសទទួលយកបណ្ដឹងសាទុក្ខនេះ និងធ្វើមោឃភាពសេចក្ដីសម្រេចដែលរងការជំទាស់នេះ[28]។

10. មេធាវីការពារក្ដីបានតវ៉ាយ៉ាងខ្លាំងថា ខ្លួននឹងទទួលរងផលប៉ះពាល់ដែលមិនអាចជួសជុលបាន ប្រសិនបើមេធាវីការពារក្ដី ត្រូវបានបង្ខំឱ្យសួរដេញដោល Philip SHORT និង Elizabeth BECKER មុនពេលការចេញសេចក្ដីសម្រេចថ្មីស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី អាស្រ័យហេតុនេះ មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តារារាំងកុំឱ្យមានករណីបែបនេះកើតមានឡើង។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ចាប់តាំងពីការដាក់បណ្ដឹងសាទុក្ខ និងសារណាបន្ថែម ស្ថានភាពបានវិវត្តន៍បន្ថែមទៀតថា ការកើតឡើងដែលមេធាវីការពារក្ដីមានការបារម្ភ នឹងមិនកើតមានឡើងនោះទេ។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចថ្មីស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[29] ដែលនៅពេលចេញសេចក្ដីសម្រេចថ្មីនេះ អ្នកជំនាញ Philip SHORT និង Elizabeth BECKER មិនទាន់ត្រូវបានស្ដាប់សក្ខីកម្មនោះទេ។ អ្នកជំនាញ Philip SHORT ត្រូវបានស្ដាប់សក្ខីកម្មចាប់ពីថ្ងៃទី ០៦ ដល់ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ គឺក្រោយ១០ ថ្ងៃនៃការចេញសេចក្ដីសម្រេចថ្មីនេះ[30]។ Elizabeth BECKER មិនទាន់ត្រូវបានស្ដាប់សក្ខីកម្មនៅឡើយនោះទេ។ ដូចនេះ មេធាវីការពារក្ដីទទួលបានយ៉ាងមានប្រសិទ្ធិភាពនូវដំណោះស្រាយដែលខ្លួនស្នើសុំពីអង្គជំនុំជម្រះតុលាការកំពូល។ អាស្រ័យហេតុ បណ្ដឹងសាទុក្ខត្រូវចាត់ទុកជាអសារបង់ និងគប្បីត្រូវបានបដិសេធចោល ដោយមិនចាំបាច់សម្រេចអំពីភាពអាចទទួលយកបាន ឬអង្គសេចក្ដីនោះទេ។

---

[27] សារណាបន្ថែម កថាខណ្ឌ៨-៩, ១៥-២៥។

[28] បណ្ដឹងសាទុក្ខ កថាខណ្ឌ៥៩។ *សូមមើលផងដែរ* បណ្ដឹងសាទុក្ខ កថាខណ្ឌ៥, ២៦, ៣៥, ៥៣។ សារណាបន្ថែម កថាខណ្ឌ ៩, ២៦, ២៨។

[29] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារE284 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

[30] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារE1/189.1។ ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារE1/190.1។ ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារE1/191.1 *និង*ប្រតិចារឹក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ E1/192.1។

11. យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ បដិសេធ** បណ្តឹងសាទុក្ខចោលជាអសារបង់។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**